# ល្បើកទូស្មានកូនចៅចិន

ដោយ អ៊ិង ខេង

បុព្វបទ ដោយ បណ្ឌិតសភាចារ្យ ឃីងហុកឌី

# កថាមុខ

**ល្បើកទូឆ្នានក្រុងចៅចិន** នេះបោះពុម្ពនៅពុទ្ធសាសនបណ្ឌិត្យក្នុងឆ្នាំ១៩៣៥មាន៣៣ទំព័រ ខ្នាតតូចហើយបានយកមកបោះពុម្ពលើកទី២នៅឆ្នាំ១៩៥៨។ ល្បើកនេះនិពន្ធឡើងជាកំណាព្យបទពាក្យ៧ដោយ អុិង-ខេងនៅឃុំកំពង់ចិន ស្រុកស្ទោង ខេត្តកំពង់ធំ។

ជីវប្រវត្តិសង្ខេបលោក **អុិង-ខេង** ជាកវីបណ្ឌិតខ្មែរក្នុងរជ្ជកាលហ្លួងស៊ីសុវត្ថិ មុនីវង្សបាននិពន្ធ **ល្បើកទូឆ្នានក្រុងចៅចិន** នាឆ្នាំច ពុទ្ធសករាជ២៤៧៧ គឺ ត្រូវនឹងថ្ងៃទី១៨ខែសីហាគ្រឹស្តសករាជ១៩៣៤ដូចមានសេចក្តីបញ្ជាក់នៅក្នុងសេចក្តីផ្តើមស្រាប់ ពោលគឺនៅពេលដែលទើបនឹងបង្កើតពុទ្ធសាសនបណ្ឌិត្យ[1]។ អុិង-ខេង ជាកូនចៅចិនតែជាប់ឈាមចិនឆ្ងាយដោយលោកបានបញ្ជាក់ថា ‹ជីតាទួតលួត› ជាចិនឆៅបានមកជ្រកកោនក្រោមម្លប់ព្រះចៅចមគោកធ្លក (កម្ពុជា)។[2]

---

[1] សូមអាន ប្រវត្តិសង្ខេបពុទ្ធសាសនាបណ្ឌិត្យ, *The Buddhist Institute, Phnom Penh A Short History*, ភ្នំពេញ, ពុទ្ធសាសនាបណ្ឌិត្យពុទ្ធសាសនាបណ្ឌិត្យ, ២០០៥។

[2] សូមអាន ឃីងហុកឌី, រស្មីកម្មអក្សរសិល្ប៍ចិនលើកម្ពុជានាសតវត្សទី១៩និងទី២០, បណ្ណាគារអង្គរ, ២០០៨,១៦៦ទំព័រ។ Cf. Jacques NEPOTE & KHING Hoc Dy, « Chinese Literary influence on Cambodia in the 19th and 20th centuries », In : Claudine SALMON (Ed.), *Literary Migrations.Traditional Chinese Fiction in*

**អ៊ុង-ខេង** បានបញ្ជាក់នាមមាតាបិតានៅសេចក្ដីបញ្ចប់ (ទំព័រ៣០)៖

បិតានាម **អ៊ុង-ស៊ុន**

មាតានាម **អេង**។ លោកប្រហែលជាកើតនៅរវាងឆ្នាំ ១៨៨០។

លោករៀបរៀង **ល្បើកាទូន្មានកូនចៅចិន** នេះឡើង ដោយចង់ទូន្មានកូនចៅចិនទាំងឡាយឱ្យចេះគោរពច្បាប់ទម្លាប់ ទំនៀមខ្មែរ, គោរពព្រះពុទ្ធសាសនាដូចជនជាតិខ្មែរជាម្ចាស់ស្រុក ដែលបានទទួលឱ្យមកជ្រកកោនរួមរស់ជាមួយ។

លោកបានបង្ហាញសមិទ្ធិនានាដែលទាក់ទងនឹងព្រះពុទ្ធសាសនាជំនាន់នោះ គឺមាន **ព្រះរាជបណ្ណាល័យ**, ព្រះសង្ឃបានចាប់បកប្រែបាលីមកជាភាសាខ្មែរដូចជាគម្ពីរ**ព្រះត្រៃបិដក** និងផ្ដើមស្ថាបនា **វចនានុក្រមខ្មែរ**[3] ដោយប្រមូលបង្កើតជាគណៈកម្មការក្រុមជំនុំ**ព្រះត្រៃបិដក**[4] និង **វចនានុក្រមខ្មែរ**ជាដើម។

---

*Asia (17-20th centuries)*, Beijing, International Culture Publishing Corporation, 1987, p. 321-372.

[3] **វចនានុក្រមខ្មែរ**, បោះពុម្ពផ្សាយជាដំបូង គឺ ភាគ១ ពី អក្សរ **ក** ដល់ **ម** នាឆ្នាំ១៩៣៨ ហើយភាគ២ ពី អក្សរ **យ** ដល់ **អ** បោះពុម្ពផ្សាយនាឆ្នាំ១៩៤៣។

[4] គណៈកម្មការ **ព្រះត្រៃបិដក** ចាប់ផ្ដើមនាឆ្នាំ១៩២៩មានព្រះសង្ឃនិងគ្រហស្ថ ចំនួនទាំងអស់ជាងសែសិបរូប។ ភាគទី១ **ព្រះត្រៃបិដក** ចេញផ្សាយបាននៅឆ្នាំ១៩៣១ប៉ុណ្ណោះ។

នៅសម័យអាណានិគមបារាំងសេស អជ្ញាធរបារាំង បានតែងតាំងលោក**អ៊ុង-ខេង** ជា **អុងចាង**[5] នៅឃុំកំពង់ចិនស្រុកស្អាងខេត្តកំពង់ធំដើម្បីធ្វើទំនាក់ទំនងរវាងជនជាតិចិននិងរដ្ឋបាលអាណានិគមព្រោះលោកចេះភាសាខ្មែរជ្រៅជ្រះ ព្រមទាំងចេះភាសាចិនផងហើយម្យ៉ាងទៀតលោកជាអ្នកមានមុខមាត់នៅតំបន់នោះ។

**អ៊ុង-ខេង** ជាបញ្ញាជនខ្មែរមួយរូបនៅជំនាន់អាណានិគមដែលមានកម្រិតវិជ្ជានិងវប្បធម៌២រួមនិងចក្ខុវិស័យខ្ពស់គួរគោរព។ លោកបានធ្វើដំណើរតាមក្រុមព្រះសង្ឃមួយចំនួន(គឺក្នុងចំណោមនោះមានព្រះភិក្ខុ**ជួនណាត**[6] )ដល់ទីកន្លែងដែលព្រះសម្មាសម្ពុទ្ធព្រះអង្គប្រសូត្រ និង ទីកន្លែងដែលព្រះអង្គទ្រង់ត្រាស់ដឹង។ល។ ពេលត្រឡប់មកស្រុកកំណើតវិញលោកបាននាំដើម **ពោធិព្រឹក្ស**មួយដើមមកដាំមុខផ្ទះ ជាអនុស្សាវរីយ៍ ហើយលោកបានបង្កើតរបរ បណ្ណាគារជាដំបូងនៅឃុំកំពង់ចិនស្រុកស្អាង។ បណ្ណាគារលោកមានលក់សៀវភៅធម៌យកពីពុទ្ធសាសនបណ្ឌិត្យនិងសៀវភៅនានាទៀត។

ដោយចង់គោរពដល់វិញ្ញាណក្ខន្ធ អ្នកចេះដឹងក្នុងឃុំស្រុកយើងយកសៀវភៅ **ល្បើកាទុង្ហានកាហ្វូងចៅចិន** មកផ្សាយឡើង

---

[5] ចំពោះជនត្តូនាទីជាតិចិននៅកម្ពុជាសូមអាន William E. WILLMOTT, *The Chinese in Cambodia*, Vancouver, University of British , 1967,; W.E. WILLMOTT, *The Political structure of the Chinese community in Cambodia*, London, Athlone Press/University of London, 1970.

[6] កាលនោះព្រះអង្គមានសមណៈសក្តិ ជាព្រះគ្រូសង្ឃសត្ថានៅឡើយ។

*វិញដើម្បីទុកជាកេរទៅថ្ងៃក្រោយទៀតកុំឲ្យបាត់បង់គតិបណ្ឌិត លោក***អុង់ថាង់ អ៊ុង-ខេង*** *នេះ។*

*សូមឧទ្ទិសអត្ថបទនេះដល់វិញ្ញាក្ខន្ធបុព្វការីនៅឃុំកំពង់ចិន ស្រុកស្ទោងខេត្តកំពង់ធំឲ្យបានសោយសុខនៅសុគតិភព។*

*ថ្ងៃទី៥ មិនា ២០១៦*

*បណ្ឌិតសភាចារ្យ* **ឃីង់ហុកឌី**

សៀវភៅទូន្មានកូនចៅចិន

អ៊ិង–ខេង

នៅផ្សារស្អាង ឃុំកំពង់ចិន ស្រុកស្អាង

ខេត្តកំពង់ធំ ជាអ្នកតែងនិងរៀបរៀង

កុង្សីយសេនាបតីបានអនុញ្ញាតហើយ

សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

បោះពុម្ពគ្រាទី ២

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស. ២៥០១

ASE 1…

CENTRE DE DOCUMENTATION ET RECHERCHES SUR L'ASIE DU SUD-EST ET LE MONDE INDONESIEN
BIBLIOTHÈQUE

សៀវភៅទូន្មាន

កូនចៅចិន

សៀវភៅទូន្មានកូនចៅចិន

កាព្យពាក្យ ៧

---

ស្រុកស្អាងនៅថ្ងៃប្រាំបីកើត ខែស្រាពណ៍ខាន
ខ្មែតបងស័ក ពីរពាន់បួនរយចិតសិបជាក់ មានថ្នាក់
ប្រាំពីរជាអវសាន ។ ថ្ងៃគ្រិស្តសករាជជប់ប្រាំបី ខែ
អ៊ិតឆ្នាំថ្មីជាប្រមាណ មួយពាន់ប្រាំបួនរយមិនស្មាន
សេសខានសាមសិបបួនវស្សា ។ អហំនាម "ខ" ផ្សំ
ស្រៈ "អេ" តួ "ង" បន្ថែមចុងអក្ខរា ត្រកូលហៅអ៊ឹងជា
ពង្សា មាតាបិតាសន្ដតមក ។ ជីតាទួតលួតជាតិចិននៅ
បានចូលមកនៅសូមគោនជ្រក ក្រោមម្លប់ព្រះចៅចម
គោកធ្លក ប្រោសប្រាណឲ្យជ្រកក្រោមបារមី ។ កូន

# BONS CONSEILS

## AUX SINO-CAMBODGIENS

POÉME COMPOSÉ

PAR

**ING KHÉNG**

Cette Publication a reçu l'approbation du Conseil des Ministres et des deux Chefs de Secte

Deuxième Édition

PHNOM-PENH

Édition de l'Institut Bouddhique

1958

ក្រុងខេមរៈកម្ពុជា យូរយារបង្កើតបុត្រា-ត្រី ជំណាតៗ
រៀងជាតិ កើតចៅប្រុសស្រីតវង្សឆ្ងាយ ៗ ដរាបរៀង
មកដល់ខ្លួនខ្ញុំ ព្រះគុណធ្ងន់ពុំអាចអធិប្បាយ ប្រោស
ប្រាណឲ្យបាននៅស្រុកកាយ ជាតិបិនតាំងឆ្ងាយ
តាំងពីមុន ៗ ហេតុនេះខ្ញុំសូមពោលថ្វាថ្លែង សំដែង
រំឭកទឹកដល់គុណ ព្រះរត្នត្រ័យថ្លៃជាមុន នូវគុណ
មាតានឹងបិតា ៗ នូវគុណសម្តេចព្រះទ្រង់ពង្ស ទ្រង់
ឫទ្ធិអំណាចនាលោកា ក្រុងកម្ពុជាមានបេស្តា ថ្លៃថ្លា
បំឡែកទុក្ខមហាជន ៗ ព្រមទាំងអស់លោករដ្ឋមន្ត្រី
ត្រួតការផែនដីគ្រប់ជំពូក អាណាខេត្រស្រុកឃុំរយ
ពាន់ ឮលាន់កិត្តិយសខ្ពស់អនេក ៗ ទ្រង់ជុសទាក់
ពុទ្ធសាសនា ឲ្យបានភ្លឺថ្លាជាថ្កើង ទំនុកបំរុង



ទ្រង់ចាត់ចែក បំណែកបំណេះខាងសាសនាៗ ដល់
បណ្ដារាស្ត្រទាំងប្រទេស ពុំមានសល់សេសខេត្រ
ស្រុកណា ក្នុងកម្ពុជាពេញសីមា ឲ្យកើតបញ្ញាទាំងប្រុស
ស្រី ៗ ទ្រង់តាំងបង្កើតនូវសាលា ព្រះរាជបណ្ណាល័យ
ជាថ្មី តាំងលោកអ្នកប្រាជ្ញប្រែបាលី ឲ្យបានសេចក្ដី
ជាពាក្យខ្មែរ ៗ ទើបយើងរាល់គ្នាបានជ្រះថ្លា ក្នុងពុទ្ធ-
សាសនាតាមនោះដែរ ព្រះគុណមហាធ្ងន់ដូចសុមេរុ
ប្រាប់ប្រែសេចក្ដីស្គាល់ខុសត្រូវ ៗ សព្វគ្រប់អន្ទើគ្មាន
បន្ទោះ ក្រមុំកម្លោះចាស់សក់ស្កូវ មិនថារូបណាបេះតែ
ត្រូវ ជម្រូវឲ្យរៀនមានគ្រប់បែប ៗ ទាំងភេទសមណៈ
ភិក្ខុសាមណេរ បាតិមោក្ខពាក្យប្រែជាសង្ខេប អនា-
គារវិន័យមានបទបែប សង្ខេបពិស្ដារតាមទំនើង



ឯភេទគ្រហស្ថក៏មានគ្រប់ ក្រោមម្លប់សាសនាពួកអស់
យើង គិហិបដិបត្តិហាត់ចុះជើង ស្រុកគេស្រុកយើង
សូត្រត្រូវគ្នា ៗ នឹងធម៌ឯទៀតជាច្រើនកង ព្រះរាជបំ-
ណាន់អាចធានា បោះពុម្ពផ្សាយឲ្យយើងរាល់គ្នា នាំគ្នា
ប្រតិបត្តិត្រង់តាមផ្លូវ ៗ គន្លងព្រះពុទ្ធសាសនា មិន
ឲ្យសាក៏ខុសជាត្រូវ ដោយល្ងោយព្រោះធ្លាប់ពីម៉ែឪ
ត្រង់ណាដែលត្រូវ ១ កាន់យក ៗ ត្រង់ណាដែល
ខុសជម្រុះចោល មិនល្បោលប្រមូលមៅតែយក ទាំង
ខុសទាំងត្រូវមិនរិះរក ជាប់មកជាកេរ្តិ៍ពីដូនតា ៗ
បិដកទាំង ៣ កំពុងបោះ មួយចប់មានឈ្មោះបីមាតិ-
កា ព្រះសូត្រវិន័យអភិធម្ម ទ្រង់ព្រះសទ្ធាចាយ
រាជទ្រព្យ ៗ ទំនុកបំរុងជួយសាសនា បើមានឈ្មោះ



ណាជាមួយចប់ ដំឡៃពីររយហាសិបគ្រប់ មួយចប់
មានមួយរយជប់ក្បាល ៗ សៀវភៅយ៉ាងក្រាស់ត្រ-
ចះថ្លា អ្នកប្រាជ្ញរចនាយ៉ាងវិសាល វិសេសស្អាត
បែបសួរគេអាល មួយក្បាលប្រាំថ្ងៃមើលមិនចប់ ៗ
សៀវភៅតូចធំជាច្រើនទៀត នឹងធ្មៀតរៀបរាប់មិន
គ្រប់សព្វ គ្រប់សាស្ត្រដែលធ្លាស់គេមិនស្អប់ គេចូល
សេពគប់ទំសិក្សា ៗ រៀនធ្វើទានសីលបេះបំណាន
គេបានឡើងកាន់វិបស្សនា សមាធិចិត្តជាឯកគ្គតា
បញ្ញាចាក់ធ្លុះលុះកម្មដ្ឋាន ៗ មិនថាសាស្ត្រណាជា
សាស្ត្រណា អ្នកមានប្រាជ្ញាគេរាប់អាន តែអ្នកល្ងង់
ខ្លៅនៅប្រមាណ ប្រមាថពោលស្មានមិនខានឈប់ ៗ
ជាធម៌ក្លែងក្លាយខុសបុរាណ គ្មានបានពិនិត្យឲ្យសព្វ

គ្រប់ ទោសៈមោហៈមកខ្ទាំងខ្ទប់ ដូចយប់ងងឹតឥតឥត
សំគាល់ ។ ត្រឹមតែសីលជប់ពីដូនតា នច្ចគីតទុច្ចាមិន
ទាន់ស្គាល់ ជាតរូបកាន់ប្រាក់គ្មានទើសទាល់ មិន
ដែលពិគាល់ថាសីលទាស់ ។ សិក្ខាពីររយម្ភៃប្រាំពិល
ថាខ្ជិលចង់ដឹងព្រោះច្រើនណាស់ បួសព្រានលេង ។
បែរក្រឡាស់ ធម៌ណាដែលច្បាស់ថាធម៌ថ្មី ។ គាគា-
រវិន័យយកាស ស្តេចមន្ត្រីក្រុមទាំងប្រុសស្រី ជា
ធម៌សម្រាប់គ្រប់ជាតិ គប្បីស្គាល់ច្បាស់លះអវិជ្ជា ។
សេចក្តីខ្លៅល្ងង់ទ្រង់តិះដៀល ដំនៀលដល់ពួកពាល
ពាលា ឯពាលគឺខ្លៅគ្មានវិជ្ជា ធ្វើតាមតែគ្នាគាមក ។
មិនថារូបណាជារូបណា អ្នកមានបញ្ញាគួររិះរក ហោល
ខុសយកត្រូវប្រមូលមក ស្វែងរកផ្លូវល្អកុំជរកាយ ។



ខ្ញុំបាទសូមទោសអស់លោកអ្នក កុំបីអន់អាក់គិត
ជិនណាយ ថាខ្ញុំប្រដៅលោកទាំងឡាយ ជាតិខ្មែរ
ស្រុកអាយមិនមែនទេ ។ តែខ្ញុំមានចិត្តគិតសង្វេគ
ដល់ជាតិខ្ញុំពេកដោយរិះរេ កូនចិនចៅចិនទាំងយើង
គេ ហេតុបុណ្យបុព្វេបានមកគប់ ។ ក្នុងល្វែង
ព្រះពុទ្ធសាសនា ដោយសារបានមកជ្រកក្រោមម្លប់
មណ្ឌលព្រះចៅព្រះបមកត ជាម្លប់កំពូលលើផែនដី ។
ហៃអស់កូនចៅចិនទាំងឡាយ ចូរស្តាប់អធិប្បាយកាយ
សេចក្តី និពានពន្យល់ជនប្រុសស្រី គប្បីតាំងចិត្តគិត
ឲ្យមាំ ។ គួរមានគំនិតពិចារណា គួរប្រើបញ្ញាយក
មកគាំ គួរផ្ទៀងត្រចៀកស្តាប់ឲ្យមាំ ចំណាំឲ្យជាក់
ក្នុងគាថា ។ ជាពុទ្ធភាសិតពិតចំពោះ ពិរោះជាងអស់



សាស្ត្រណា ៗ ក្នុងលោកទាំងបីមានទេវតា ព្រហ្ម-
នុស្សជាបរិស័ទ ។ បើខំសង្កេតគង់ឃើញជាក់ គួរ
ភ្ញាក់ជាក់ច្បាស់ដោយមគ្គ័ត ពុទ្ធសាសន៍បង្ហាញការ
ប្រតិបត្តិ នៃពុទ្ធបរិស័ទតាមក្បួនច្បាប់ ។ គម្ពីរស្លឹករឹត
ឬសៀវភៅ មាននៅតរគោកទុកសម្រាប់ សម្រាយ
ស្រាយប្រែមកឲ្យស្តាប់ សម្រាប់ប្រដៅផ្លូវត្រូវខុស ។
កុសលអកុសលបាបនឹងបុណ្យ ទោសគុណទុក្ខសុខ
គ្រប់ស្រីប្រុស កុំកាន់ទុច្ចរិតប្រព្រឹត្តខុស គប្បីខំដុស
ខាត់សុចរិត ។ គួរគិតដល់គុណព្រះករុណា
ព្រះទ័យជ្រះថ្លាទ្រង់ទសពិធ ទ្រង់ឧបត្ថម្ភជួយគំនិត
រិះគិតឲ្យកើតក្បួនវិជ្ជា ។ ដល់ពួកបណ្ដារាស្ត្រ
ស្រុកខ្មែរ ស្រុកក្រុងស្រុកស្រែផងនានា ជាទី



សង្គ្រោះយើងរាល់គ្នា ឲ្យកើតវិជ្ជាទាំងពីរឋាន ។ គឺ
លោកិយៈលោកុត្តរៈ តាមចិត្តយើងស្ម័គ្រចូលរាប់អាន
ចំណេះទាំងពីរពេញចំណាន គ្រប់ប្រាណបានប្រាជ្ញ
ព្រោះរាជការ ។ គួរយល់ដល់គុណរាជការណាស់
ឃើញច្បាស់ពីរឿងមុខពន្ធដារ ទាំងអ្នកជំនួញស្រែចំ-
ការ រាជការត្រូវទារយកគ្រប់មុខ ។ បាត់ពន្ធដីស្រែ
ចំការ នឹងថ្លៃរាជការលោះការទុក ចាត់ចែងចែកចាយ
រាយគ្រប់មុខ រៀបស្រុកធ្វើផ្លូវទៅវែងឆ្ងាយ ។ បៀវត្សរ៍
មន្ត្រីសក្តិតូចធំ ក្នុងស្រុកនិគមផងទាំងឡាយ ជាទី
ការពារក្តីអន្តរាយ ឲ្យសុខសប្បាយក្នុងសីមា ។ បើ
យើងមានទុក្ខទោសរឿងអ្វី អាចមានមន្ត្រីពិចារណា
ជំនុំជម្រះតាមមាត្រា ឲ្យបានសុខាគ្រប់រូបកាយ ។

បើមានពួកចោរចូលលុកប្លន់ ទ្រព្យធនអ្នកស្រុកផង
ទាំងឡាយ ទាហានប៉ូលិសលោកចៅហ្វាយ ខ្វល់
ខ្វាយស៊ើបចាប់គាចោរខ្លាំង ៗ យកខ្លួនមកធ្វើទោស
ផ្ដន្ទា ឲ្យរាងចាលពេញកំឡាំង ឲ្យយើងបានសុខ
និរទុក្ខ ទូទាំងអាណាខែត្រព្រះអង្គ ៗ ប៉ុន្តែបើមាន
ឈ្មោះអ្នកណា ជ្រះថ្លាចូលកាន់ភេទជាសង្ឃ ភិក្ខុ
សាមណេរតាមចំណង់ ទ្រទ្រង់ព្រះពុទ្ធសាសនា ៗ
គ្រប់វត្តនានាក្នុងខែត្រខណ្ឌ រាប់ពាន់បានចូលរាជ-
ការ សូមចេញបដិញ្ញាណសង្ឃដីកា រាជការអនុញ្ញាត
ឲ្យតាមចិត្ត ៗ លើកលែងលោះចោលប្រាក់ពន្ធដារ
រាជការមិនយកដោយអាណិត ដល់ពួកអ្នកបួសជា
បព្វជិត ហៅភិក្ខុពិតឬសាមណេរ ៗ ដើម្បីសង្គ្រោះ



ដល់ពួកជន ព្រះគុណមហាធ្ងន់ដូចឪម៉ែ លះបង់រាជ-
ទ្រព្យផ្ដាច់ឲ្យតែ ជាតិកូនចៅខ្មែររៀនវិជ្ជា ៗ ដោយ
សារបួសរៀនមានក្បួនច្បាប់ សម្រាប់សាសនាផង
នានា ទ្រទ្រង់តាមភេទនៃបព្វជ្ជា ក្នុងរាជការម្ចាស់
ផែនដីៗ ទ្រង់ចង់ចំរើនព្រះសាសនា ស៊ូលោះពន្ធដារ
ការបុរី គួរតែបួសហើយរំឭកខ្ចី រៀនសូត្របាលី
នឹងសម្រាយ ៗ ឲ្យបានដឹងជាងព្រះសាសនា បញ្ញត្ត
យ៉ាងណាទំខ្វល់ខ្វាយ ឲ្យបានដឹងច្បាស់អត្ថបរិយាយ
ទាក់ទងទាំងឡាយប្រៀនប្រដៅ ៗ ទើបអាច
ប្រតិបត្តិត្រឹមត្រូវបាន កុំធ្វើស្មានៗតាមកំឡៅ វិន័យ
ធម៌អាថ៌ការកក់ជ្រៅ នៅក្នុងបិដកទាំងបីស្រាប់ ៗ
ដូចបានសំដែងហើយខាងមុន ព្រះគុណផែនដីរៀប



សម្រាប់ សម្រេចសេចក្ដីទុកជាច្បាប់ សម្រាប់បំរុងព្រះ
សាសនា ៗ បើបួសមិនរៀនពេញអាក្រក់ ហាក់ដូច
កុហកដល់រាជការ បំណាច់លោកលោះចោលពន្ធដារ
ជាបួសសិក្សាធម៌វិន័យ ៗ ស្គាល់ខុសស្គាល់ត្រូវតាម
ពុទ្ធដីកា កាន់ក្រិត្យសិក្ខាឲ្យរាំងរៃ បើបួសលេងៗឥត
ក្រែងភ័យ គ្មានរៀនវិន័យឲ្យចាំបាន ៗ សាសនា
ប្រែថាពាក្យប្រដៅ បើចេះតែមៅពោលប្រមាណ
ធ្វើម្ដេចនឹងត្រូវតាមលំនាំ ព្រោះស្គាល់មិនបានអត្ថ
បាលី ៗ បើលោកសំដែងក្នុងបិដក ពេបជ្រាយ
សំឡក់មុខខ្វល់ខ្វី តិះដៀលពោលត្មះថាធម៌អ្វី ជាធម៌
ថ្មីៗ ទើបរឹងតែង ៗ មិនមែនបោះទេអស់កូនចៅ
ចូលទៅឲ្យច្បាស់នឹងភ្នែកឯង ទីក្រុងភ្នំពេញរាំង



ចរិញ្ចួង ខាងមុខនោះឯងបណ្ណាល័យ ៗ ជាជួរទីង
សាលាបាលី លោករដ្ឋមន្ត្រីត្រួតរៃព អ្នកប្រាជ្ញ
ប្រែធម៌តែសព្វថ្ងៃ ព្រះចៅក្រុងក្រែទ្រង់អនុញ្ញាត ៗ
ឲ្យរដ្ឋមន្ត្រីស្ដីការឃ្វាំង ចាយប្រាក់ព្រះឃ្លាំងតាំង
ក្បួនខ្នាត បិដកទាំងបីទុកជាអាទិ៍ សង្វាតជួយគាំពារ
សាសនា ៗ អាណិតជាតិយើងដែលល្ងង់ខ្លៅ
លិចលង់ផុងនៅក្នុងអវិជ្ជា អ្នកប្រាជ្ញជាន់ដើមមាន
បញ្ញា តែថាសាសនាយៀងឃ្លាតឆ្ងាយ ៗ តៗរៀង
មកលុះសព្វថ្ងៃ ព្រោះតែមិនសូវមានប្រែស្រាយ ច្រើន
តែបាលីលោកចែងចាយ អស់យើងទាំងឡាយស្ដាប់
មិនបាន ៗ មិនបែកបញ្ញាថ្វាគំនិត បើគិតក៏គិតដោយ
ការស្មាន រៀនសូត្រចេះចាំទាំងប៉ុន្មាន ជាបានបុណ្យ

ហើយគ្រន់រៀនបប់ ។ រៀនចាំតែមាត់ក្វាត់គំនិត ព្រោះគិតមិនយល់ដោយគ្រប់សព្វ ចុំនប់ន៍យកបុណ្យគ្រន់រៀនបប់ ឲ្យឡប់មុខក្រោយគ្មានដឹងអ្វី ។ សំដៅយកបុណ្យគ្រន់បេះសូត្រ បាតិមោក្ខរហូតចប់បាលី តែគ្មានបានដឹងជារឿងអ្វី ពុំយល់សេចក្ដីច្បាប់សាសនា ។ នៅក្នុងបាតិមោក្ខតាំងមូលនោះ ចំពោះបញ្ញត្តក្នុងសិក្ខា វិន័យជាឫសគល់សាសនា សិក្ខាពីររយម្ភៃប្រាំពីល ។ រៀនបប់ចាំមាត់នោះល្អណាស់ តែឲ្យដឹងច្បាស់អស់មន្ទិល សេចក្ដីសម្រាយកុំឲ្យខ្ជិល ទើបអាចមើលឃើញខុសត្រូវ ។ ប្រតិបត្តិគ្រន់តាមក្រិត្យសិក្ខា អាចញុំាងសាសនាឲ្យគ្រន់ផ្លូវ យកបុណ្យគ្រន់នេះទើបពេញត្រូវ តាមផ្លូវអដ្ឋង្គិកមគ្គ ។



ទើបពេញជាស្រែបុណ្យមហាជន បរិច្ចាគទ្រព្យធនមកពីផលពាក់ ផុតក្នុងសំពៅទៅអមតៈ រួចពីអាសវៈចេញទៅបាន ។ ឯពួកគ្រហស្ថទោះប្រុសស្រី កើតក្នុងលោកិយទាំងប៉ុន្មាន ពេញមហាលាភធំរកក្របាន នាំប្រាណមកជួបពុទ្ធសាសន៍ ។ គួរណាស់កូនចៅទាំងឡាយអើយ កុំធ្វើកន្តើយប្ញូររហ័ស រៀនសូត្រធម៌អាចឲ្យចាំច្បាស់ រហ័សធ្វើទានសីលភាវនា ។ គោរពកោតខ្លាចលោកអ្នកចាស់ មានវ័យគ្រាលក្រាស់ជាព្រឹទ្ធា ធ្វើការបំរើសព្វនានា កាលគ្រាធ្វើបុណ្យរួចជូនផល ។ ដល់អ្នកដ៏មានគុណទាំងឡាយ គឺម្ដាយឪពុកទុកដំកល់ អនុមោទនាយកកុសល ចំណែកបុណ្យផលឲ្យបានទៀត ។ សំដែងធម៌អាចឲ្យ



គេស្ដាប់ ពន្យល់តាមសព្វពាក្យគន្លៀត ប្រឹងស្ដាប់យកដោយខ្លួនឯងទៀត ហើយត្រៀតប្រដៅចិត្តឯងផង ។ ឯបុញ្ញកិរិយាទាំងដប់នេះ ជាយានជំនិះជិះចំឡង ឲ្យរួចចាកចេញពីចំណង សង្សារវដ្តចងជាប់ច្រើនជាតិ ។ ច្រើនជាន់វ័ណ្ណធាក់ធ្លាក់អបាយ យូរឆ្ងាយខ្លួលាយមិនអាយឃ្លាត កើតស្លាប់រាប់មិនសែនលានជាតិ ព្រោះតែមារយាទជួល្ងង់ខ្លៅ ។ ពេលនេះគួរដឹងភ្ញាក់ខ្លួនបាន ដោយមានអ្នកប្រាជ្ញប្រៀនប្រដៅ មិនគួរនាំគ្នាដេកតែខ្លៅ មួម៉ៅនឹងប្រាជ្ញប្រែបរិយាយ ។ ពន្យល់បង្ហាញផ្លូវរៀបគ្រន់ មិនចង់ចូលជិតចៀសវាងឆ្ងាយ គ្មានគិតអាណិតដល់រូបកាយ មិនស្ដាយកំណើតជាតិនៃខ្លួន ។ ដែលបានកើតមកជួបសាសនា



ចួនលើកដការតែងច្បាប់ក្បួន គម្ពីរដីកាពេញសំនួន កុំអីធ្លាក់ខ្លួនជាតិរច្ឆាន ។ អសោចលើសខ្មោចកណ្ដាលព្រៃ គ្មានភ័យទឹងទោសក្នុងសន្ដាន រៀនសូត្រធម៌អាចថាស្ទាន ។ សីលទានធ្វើប្រាណលើអាចារ្យ ។ គ្រន់ការខុសត្រូវមិនសូវគិត ប្រគល់គំនិតលើលោកតា លោកទាញទៅដាក់ថ្នាក់ជាន់ណា ស្រេចទឹងប្រាជ្ញាបេះតែបាន ។ ពេលស្លាប់ទៅប្រាប់លោកអាចារ្យ ឲ្យធ្វើបនស្រោធ្វើកម្មដ្ឋាន នាំផ្លូវទៅដាក់សួគ៌ឲ្យបាន ដល់ឋានតាគង់ជានាយទ្វារ ។ គួរឬតាគង់អាយរង់កម្ម ឈរចាំតែប្រាប់ឋានមាគ៌ា ទាំងថ្ងៃទាំងយប់គ្រប់វេលា ចាក់សោបើកទ្វារនាំដាក់ផ្លូវ ។ មិនដឹងជាមានធម៌បែបណា អាចារ្យបេះដឹង

នាំជម្រូវ ជម្រង់លើកដាក់ទំលាក់ផ្លូវ ឲ្យត្រូវទៅ
លើសួគ៌និព្វាន ។ ព្រះពុទ្ធជាម្ចាស់ត្រាស់ទេសនា ជា
ឲ្យខស្បាហ៍ធ្វើសីលទាន កាន់ក្តីសុចរិតកុំឈ្លានពាន
ឲ្យមានសីលប្រាំទីនកម្មបថ ។ ប្រយ័ត្នទ្វារកាយវាចា
ចិត្ត ប្រព្រឹត្តខ្លួនឯងឲ្យហ្មត់ចត់ កតញ្ញូខន្តីអំណត់
បានមុខសប្តំតាំងកម្មដ្ឋាន ។ លះនីវរណៈជាសត្រូវ
នឹងផ្លូវសមាធិជាប្រធាន ឲ្យស្ងប់រម្ងាប់ចិត្តក្សេមក្សាន្ត
ទើបបានក្តីសុខផុតទុក្ខា ។ មិនព្យាថាគេធ្វើជួសបាន
នាំប្រាណទៅដាក់ឋានទេវតា ហាក់ដូចពោលជ្រួស
ហួសពុទ្ធដីកា ដូចលោកអាចារ្យបេះជាន់ព្រះ ។ ឯកន់
គម្ពីរវិសុទ្ធិមគ្គ ជាច្បាប់ដាក់លាក់ត្រឹមត្រូវណាស់
តាំងពីបុរាណគម្ពីរចាស់ មិនដែលប្រែផ្លាស់ចាស់ថ្មី ។



ជាក្បួនសមាធិកម្មដ្ឋាន បុរាណចារឹកជាបាលី អ្នក
ប្រាជ្ញប្រែសំរួលប្រាប់សេចក្តី ចេញពីបាលីឲ្យឃើញ
ស្ដែង ។ ពន្យល់ដល់យើងដែលងងឹត មិនអាចនឹង
គិតឃើញខ្លួនឯង ធម៌អាថ៌លោកណា នឹងហ៊ានក្លែង
អ្នកប្រាជ្ញលោកតែងតាមគម្ពីរ ។ ក្នុងផ្លូវបិដកតាំងមូល
នោះ លោកបានពិគ្រោះឃើញខុសខ្លី ជំនុំយល់
ព្រមគ្រប់ពេញទី គណៈសង្ឃពីរយល់ព្រមផង ។
នៃអស់កូនចៅទាំងប្រុសស្រី កុំស្តីផ្តេសផ្តាសក្រែង
មានហ្មង កុំកាន់ប្រកួតអួតប្រឡង ដដែកម្តង ។ ស្មើរ
បែកស្រុក ។ ខ្លះអួតធម៌ចាស់ខ្លះអួតថ្មី ទាំងប្រុស
ទាំងស្រីកើតអុកឡុក កាន់ពួកកាន់ក្រុមគ្រប់តែស្រុក
មិនបេះបានសុខមូលមាត់គ្នា ។ សាសនាព្រះពុទ្ធតែ



មួយអង្គ លោកសង្ឃកាន់ក្រឹត្យបែកសមគ្គា បាសក
កាន់ពួកខុសបែបគ្នា វិន័យធម្មាមានតែមួយ៉ាង ។ ចូរ
មើលគម្ពីរឲ្យប្រាកដ មានបទគាថាទុកជាសាង អ្នក
ប្រាជ្ញសំដែងថែងដោយយ៉ាង មានកាងគម្ពីរគ្រប់
មាតិកា ។ បើនៅសង្ស័យត្រូវបញ្ឈាក់ ឲ្យដឹងតាម
វគ្គគម្ពីរណា ត្រូវមើលឲ្យច្បាស់នឹងនេត្រា កុំថាតែ
មាត់យាត់មិនស្តាប់ ។ ឲ្យស្ទាត់បាត់ឆ្ងល់ពីនេះទៅ
ឯធម៌សៀវភៅជាក្បួនច្បាប់ រាជការអនុញ្ញាតខាងខ្នង
ស្រាប់ ប្រថាប់ទាំងគ្រាបណ្ណាល័យ ។ ជាគោលចារឹក
ព្រះសាសនា កុំកូនចៅណានៅសង្ស័យ ចូរខំរៀន
សូត្រទាំងយប់ថ្ងៃ នឹងមាននិស្ស័យក្នុងសាសនា ។
អនាគតកាលឯមុខគ្រាន់ ទុកជាមិនទាន់បានស្រោតា



ទីអរិយមគ្គថ្នាក់ជាន់ណា គង់បានសុខាជាលំដាប់ ។
មិនបង់ខ្លួបជាតិខ្លួបកំណើត បានកើតជាមនុស្សពេញ
មានភ័ព្វ កុំឲ្យប្តូរធ្លោយដោយសារធ្លាប់ មិនអាប់
ពីព្រោះរៀនធម៌ប្រែ ។ មិនក្រពីព្រោះរក្សាសីល
បើក្រព្រោះខ្ជិលមិនធ្វើស្រែ ឬខ្ជិលមិនគិតរកជួញប្រែ
គិតតែប្រកួសធម៌ចាស់ថ្មី ។ អ្នកប្រាជ្ញមានគុណមាន
បញ្ញា ខស្បាហ៍ខំរៀនធម៌វិន័យ កុំអាងអួតបេះតែ
ក្នុងព្រៃ ឥតនឹកមមៃខ្មាសបណ្ឌិត ។ កុំជឿតាមពាក្យ
ពាលកំឡៅ អ្នកប្រាជ្ញប្រដៅត្រូវឲ្យគិត កុំតាមពួក
ពាលខូចគំនិត ត្រូវគិតតាមប្រាជ្ញប្រែបាលី ។ កុំគប់
នឹងមនុស្សជឿអារក្ស ក្រែងធ្លាក់ទៅក្នុងអវិចី ជឿ
សរណគមន៍គុណទាំងបី សីលប្រាំ-ប្រាំបីប្រសើរ

ណាស់ ។ អ្នកប្រាជ្ញជាន់ណាគន់សរសើរ នេះគឺ
ដំណើរគន្លងព្រះ កុំព្រើលទៅតាមពួកពាលមានះ
បង់ព្រះសំពះឯបាយាំច ។ ទៅពឹងអារក្សនឹងអ្នកតា
ប្រាថ្នាយកបុណ្យបង់រួចបាប គ្មានខ្មោចអារក្សណា
បេះទាច ឲ្យរួចពីបាបកម្មទៅបាន ។ ស្រេចតែនឹង
ខ្លួនទីពឹងខ្លួន កុំកួនប្រទូស្តដូចតិរច្ឆាន ពានសីល
សមាធិកម្មដ្ឋាន អ្នកណាគិតអានបានអ្នកនោះ ។
មគ្គផលមិនដែលកើតសៀម ។ ដេកត្រៀមចាំផល
ឲ្យបានលុះ ធម៌អាថ៌សង្ស័យមិនបេះធ្លុះ តាមនេះក្រែង
នោះមិនស្រេចការ ។ សង្ស័យនឹងធម៌ជាច្បាស់
អ្នកប្រាជ្ញប្រែច្បាស់មិនត្រូវការ មិនបេះយល់ព្រម
តាមអ្នកណា ចេះធ្វើដើរឈ្មោះពីព្រោះខ្ទ ។



គេថាឯស្ដាំចាំទៅធ្វេង សំដីអួតក្អេងអាងកំឡៅ
ខ្លាចថាគមិនស្ដាប់ប្រាជ្ញប្រដៅ ខ្លាចគេមិនហៅ
លោកអាចារ្យ ។ សន្ធើបបែបខ្មៅតែប៉ុណ្ណោះ ដំណា
ពីនេះសូមពណ៌នា ចំពោះកូនចៅអ្នកសិក្សា ដែល
មានប្រាជ្ញារៀនគ្រង់គ្រាប់ ។ ចាំងកេចបញ្ជិតយក-
រស អ្នកឈ្លាសរាងវៃសូមផ្ទៀងស្ដាប់ កុំអាងតែប្រាជ្ញ
មិនខ្លាចបង្អាប់ កុំប្រែក្រឡាប់មើលងាយចាស់ ។ កុំ
អាងខ្លួនរៀនចេះចាំគ្រាន់ លោកជាន់លើគេមិនក្រែង
ខ្លះ មិនខ្លាចអំណាចអាជ្ញាព្រះ ពោលព្រានអាង
ច្បាស់មួយសៀវភៅ ។ គួរគិតអាណិតដល់អ្នកល្ងង់
ឃើញគ្នាលិចលង់ផុងចុះជ្រៅ គួរតែស្រោចស្រង់ផ-
ម្រង់ផ្លូវ កុំប្រានគ្នាទៅឲ្យក្ដៅចិត្ត ។ ឯលោកអ្នកចេះ



ធម៌វិន័យ គួរមានមេត្រីក្ដីអាណិត អាសូរដល់អ្នកខ្មៅ
ងងឹត ជួយគិតដឹកនាំគ្នាទៅផង ។ កុំបេះបន្តិចកំប៉ិច
ឡើង ឬកន្ដើងកន្ត្រើនខុសល្បត់ល្បង ធម្មតាអ្នក
ប្រាជ្ញខ្លាចសៅហ្មង មិនហ៊ានកន្លងច្បាប់មាត្រា ។
បួសជាភិក្ខុខ្លាចអាបត្តិ វិន័យបញ្ញត្តិហាមយ៉ាងណា
ប្រព្រឹត្តធ្វើតាមគ្រប់សិក្ខា ទើបបានហៅថាសង្ឃបរិ-
សុទ្ធ ។ សាមណេរខ្លាចទោសទណ្ឌកម្ម វត្តបិតសិប
ប្រាំទីបំផុត ឈ្មោះសេក្ខិយវត្តច្បាប់កុលបុត្រ ត្រូវ
ទំលំអុតប្រព្រឹត្តតាម ។ គ្រហស្ថត្រូវខ្លាចដាច់សីល
ប្រាំ ឧបោសថកម្មព្រះផ្ដាំហាម ជួញប្រាំកម្មបថ
កំណត់តាម កុំឲ្យមានស្នាមជុះធ្លាយឡើយ ។ ទើប
បានឈ្មោះថាពុទ្ធបរិស័ទ នឹងឆ្លងវិមុត្តិទៅដល់ត្រើយ



ព្រោះបានធ្វើត្រូវតាមផ្លូវហើយ នឹងបានសះស្បើយ
ចាកទុក្ខភ័យ ។ តែថាកុំទ្រង់ត្រឹមទានសីល គួរ
ប្រឹងកកិលដោយមមៃ ភាវនាស្ទឹងស្មាធិ៍ស្អាតប្រពៃ
ដកចិត្តអាល័យពីត្រៃភព ។ វេលារក្សាសីលប្រាំបី
ត្រូវលៃពេលថ្ងៃឬពេលយប់ ពេលណាស្ងាត់ស្រួល
បូលប្រាវព តាំងចិត្តឲ្យស៊ប់ក្នុងកម្មដ្ឋាន ។ បំណាច់
ខំលះកិច្ចកន្ទល់ ប្រាថ្នាមគ្គផលសួគ៌និព្វាន បើនៅ
សៀម ។ ធ្វើម្ដេចបាន ដល់ទីក្សេមក្សាន្តដូចប្រាថ្នា ។
បញ្ឈប់សេចក្ដីតែប៉ុណ្ណឹង កូនណាចង់ដឹងចូរសិក្សា
សាកសួរអ្នកប្រាជ្ញឲ្យច្បាស់ការ ឃើញទាស់ត្រង់
ណាតវ៉ាទៅ ។ កុំថាផល់ច្បាប់គម្ពីរធំ សូម្បីច្បាប់
ក្រមឬកូនចៅ ពាក្យចាស់ក៏ដនេតិសន្ដេតទៅ គង់

មានប្រាប់ផ្លូវត្រូវយាត្រា ។ ធម្មបទមង្គលវិសុទ្ធិមគ្គ ក្រែងមើលមិនជាក់គ្រប់មាតិកា ព្រោះមានអ្នកខ្វះខ្វះអំនត ពោលគឺបញ្ញាជាគ្រឿងធ្លុះ ។ តែជាសូមជ្រាបដូច្នេះសិន កុំគាលសន្និស្ដីបន្ទុះ បូលគិតមុខក្រោយឲ្យសព្វសុះ គង់ឃើញត្រូវខុសនៅផ្សេងគ្នា ។ ពាក្យថាចាស់ថ្មីស្ដីកំណត់ ហៅតាមសន្មតដោយវោហារ សការៈធម៌គ្មានរូបា បានអ្វីត្រង់ណាថាថ្មីចាស់ ។ គ្រាន់តែជាពាក្យប្រៀនប្រដៅ ប្រាប់ផ្លូវក្រឡេកឥតមានខ្វះ ឯធម៌វិន័យរបស់ព្រះ យូរណាស់គ្មានចាស់ទៅណាឡើយ ។ ដូចពាក្យថាបាណាតិបាត យូរឆ្នាំច្រើនជាតិណាស់មកហើយ មិនដែលពុចាស់ស្លាប់ម្ដងឡើយ នេះហើយអមតវាចាពិត ។



ខន្ធអាយតនៈត្រៃលក្ខណ៍បី ទាំងធម៌ដទៃគួរពិនិត្យ សីលប្រាំ. ប្រាំបីក្ដីសុចរិត ជាពុទ្ធភាសិតឥតមានក្លង ។ ត្រង់ពាក្យចាស់ថ្មីសំដីមនុស្ស បេះតែវេរុះខុសទំនង ប្រកាន់ពួកក្រុមនាំសៅហ្មង ធ្វើខុសគន្លងពីបុរេ ។ ព្រះពុទ្ធជាគ្រូចាស់បុរាណ ត្រាស់ដឹងញេយ្យញាណមកមុនគេ មិនដែលដណ្ដើមចាស់ថ្មីទេ ហេតុម្ដេចធ្វេសទៅមិនធ្វើត្រាប់ ។ ឲ្យត្រូវតាមផ្លូវទៅនិព្វាន ដូចព្រះទ្រង់ញាណប្រទានប្រាប់ ប្រោសប្រៀនប្រដៅទុកនៅស្រាប់ . គួរប្រឹងប្រញាប់ឆាប់ឈានដើរ ។ ឈមមុខដម្រង់ផ្លូវប្រាំបី គន្លងព្រះអរិយដ៏ប្រសើរ ព្រះពុទ្ធគ្រប់អង្គផងដំណើរ ស្ដេចតាមដំណើរផ្លូវនោះឯង ។ ដំណើរនោះមានកាំប្រាំបី



ទោះទាំងប្រុសស្រីប្ដីចាស់ក្មេង ឡើងបានទាំងអស់ឥតរើសថែង ទូលាយធំធេងគ្មានចង្អៀត ។ ឡើងដើររហូតផុតភពបី បានដល់បុរីថ្លៃថ្លាទៀត គឺនិព្វានគ្មានកន្ទៀត កន្លែងចង្អៀតតិចតួចសោះ ។ ឯអង្គប្រាំបីនោះពុទ្ធដីកា ទ្រង់ចាត់ចូលគ្នារួមទាំងអស់ ហៅថាសិក្ខាបីប៉ុណ្ណោះ គឺសីលសមាធិបញ្ញា ។ សម្មាវាចាកម្មន្តោ នឹងអាជីវោបីប្រការ ចាត់ចូលជាសីលៈសិក្ខា តាមព្រះពុទ្ធដីកាទ្រង់ពន្យល់ ។ ឯវាយាមោនឹងសតិ នឹងសមាធិចិត្តដំកល់ សម្រឹងទន្ទឹងរង់មគ្គផល ប្រមូលកុសលទាំងប៉ុន្មាន ។ ចាត់ជាសមាធិសិក្ខា តាមដោយពុទ្ធដីកាទ្រង់ទូន្មាន ប្រដៅសព្វសត្វច្រើនកោដិលាន បានសួគ៌និព្វានរាប់មិនអស់ ។



សម្មាទិដ្ឋិសង្កប្បោ ជាទីតិរោយមានកំពស់ កំពូលវិសេសលើសទាំងអស់ នោះឈ្មោះបញ្ញាសិក្ខាស្ដែង ។ ឯអង្គប្រាំបីត្រៃសិក្ខា ដូចបានពណ៌នាមកនេះឯង ជាធម៌សម្រាប់ប្រាប់គន្លង កុំឲ្យវង្វេងពីនិព្វាន ។ ត្រង់ធម៌ចាស់ថ្មីសំដីក្លាយ មគ្គផលទាំងឡាយមិនដែលមាន ព្រោះពាក្យទាំងនោះខុសបុរាណ នាំឲ្យរំខានថយកំឡាំង ។ អ្នកបេះបរិយត្តិបិដក បើពោលកុហកគ្មានទីតាំង កាប់ពុទ្ធដីកាព្រះអរហំ ទៅសោយទុក្ខខ្លាំងក្នុងអបាយ ។ ដូចកបិលភិក្ខុជាតួយ៉ាង បេះហើយក្អេងក្អាងអាងបរិយាយ . ញុំាញីសាសនាឲ្យអន្តរាយ ធ្លាក់ទៅអបាយកាយអប្រិយ ។ ឯលោកអ្នកបេះខាងកម្មដ្ឋាន ដែលបានដល់ឈានជាលោកិយ

គង់តែធ្លាក់ខ្លួនទៅអវិចី ព្រោះក្តីប្រព្រឹត្តខុសកន្លង ។ ដូចយ៉ាងទេវទត្តស្លាត់ចំណាប់ ចូលចេញឈានជាប់ ឃើញច្បាស់ទែង បំរើនពុទ្ធាអស្ចារ្យស្តែង ខំលើកខ្លួនឯងធ្វើជាព្រះ ។ ថ្លែងរឿងនេះមកដោយសង្ខេប គ្រាន់តែជាបែបឲ្យឃើញច្បាស់ ថានសួគ៌និព្វានព្រះទ្រង់ត្រាស់ ថាច្បាស់បានព្រោះផ្លូវនេះឯង ។ ផ្លូវនេះឈ្មោះថាមជ្ឈិមា បដិបទាតាមអត្ថថែង ជាផ្លូវគ្រង់ពិតឥតមានខ្វែង ឯកឯងទីទៃពីផ្លូវឆ្វេង ។ បញ្ចប់ត្រឹមនេះតាមវេលា ខ្ញុំមាននាមាឈ្មោះអ៊ឹងខេង រីមាតាខ្ញុំនាមឈ្មោះអេង ស្មានពីក្មេងលុះសព្វថ្ងៃ ។ បិតាខ្ញុំនាមឈ្មោះអ៊ឹង-ស៊ុន កាលពជ្យសៀមមុនធ្វើ[illegible] នៅដែនសៀមពបតាមសម័យ លោកក្ស័យជន្មាជា



យូរឆ្នាំ ។ នៅតែអ្នកម្តាយមេម៉ាយចាស់ ជរាពេកណាស់កេតប្រចាំ ខ្ញុំខំសង្កាត់ស្វែងរកឆ្នាំ ថែទាំកែពេកនៃមាតា ។ ចាំទំពុទុសបតិកម្មដ្ឋាន លំអានសមថៈវិបស្សនា ព្យាយាមពប់ខ្យល់អានាបា ក្នុងវ័យបច្ឆិមាជាប្រក្រតី ។ ជាទីតបគុណដល់មាតាបិតាដែលចូលកតលោកិយ សូមឲ្យលោកបានថានសិរីដោយបុញ្ញកសិនៃធម្មទាន ។ ខ្ញុំខំប្រឹងតែងច្បាប់ប្រដៅ កូនចៅចិននេះទុកជាស្ពាន ចំឡងពួកអ្នកដែលឈ្លានពាន ឲ្យមានសទ្ធាជឿកម្មផល ។ ទានសីលការនាកល់គ្នាឡើង ជំកើងសាសនាលើកដំកល់ប្រាណគាត់មោហៈអកុសល បានដល់សទ្ធានឹងសីលា ។ សុតៈបាត;តាមលំអាន ឯបរិយោសានគឺបញ្ញា តាំង



ប្រាំប្រចាំគ្រប់រូបា សាសនានឹងរីកវុងរឿងបាន ។ គ្រប់គ្រាន់ប្រាំពាន់ព្រះវស្សា ត្រចះជ្រះថ្លាដូចសូរិ-យាន កណ្តាលវេហាអាកាសស្ថាន ឥតមានពពកមកបាំងបិទ ។ ក្នុងទីបំផុតពាក្យកាព្យ ខ្ញុំសូមប្រា-ថ្នាឲ្យមានចិត្ត ស្អប់ខ្ពើមបៀសវាងផ្លូវទុច្ចរិត ប្រព្រឹត្តសុចរិតរៀងរាល់ជាតិ ។ សូមឲ្យប្រកបដោយបញ្ញាចេះដឹងធម៌អាថ៌ការក្បួនខ្នាត រាងវៃគង់អាចក្នុងពួកញាតិ ជាជាតិត្រកូលអម្បូរខ្ពស់ ។ នៅក្នុងព្រះពុទ្ធ-សាសនា បានស្តាប់ពុទ្ធដីកាពាក្យពីរោះ សូមឲ្យខ្ញុំបានដល់ថានខ្ពស់ បំពោះនិព្វានតាមបារមី ។ ព្រមទាំងលោកអ្នកដែលទស្សនា ឬបានសិក្សាតាមសេចក្តីសៀវភៅល្បើកនេះទាំងប្រុសស្រី សូមសុខសិរីគ្រប់



ប្រការ ។ ម្យ៉ាងទៀតសូមជូនកុសលបុណ្យ ដល់អ្នកមានគុណធ្ងន់ថ្លៃថ្លា ព្រមទាំងសព្វសត្វនឹងទេវតា ឲ្យបានសុខដូចបំណង ។ មួយទៀតសូមថ្វាយជូនរាជ-ការ មានព្រះករុណាជាចម្បង អគ្គប្រមុខទ្រង់គ្រប់គ្រង មន្ត្រីរាស្ត្រផងគ្រប់កន្លែង ។ សូមបានប្រកបឡើងសក្តិបុណ្យ វិសេសជាងមុនខ្ពស់ចំពែង មានបុណ្យអំណាចអាចគ្រោមដ្រែង រក្សាដំណែងអង្វែងថ្ងៃ ។ សំដែងមិនបានជាគ្រប់សព្វ សន្មតជាចប់ពាក្យកែខៃ ពន្យល់កូនចៅជាបច្ច័យ តាមកាលសម័យចប់ ឯរ ។

ចប់ ល្បើកទូន្មានកូនចៅចិន ។